ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២៤ "គ១"

ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៥៩

ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរលេខ: ៥៥៦៧

ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ: ១៦៦៣

ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក នៅសាលសវនាការទី២ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៥៩ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ ដែលមាន៖

-ជនជាប់ចោទឈ្មោះ [redacted] KUNWAR ( [redacted] យុនវ៉ា) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិនេប៉ាល់ មានទីកន្លែងកំណើតនៅប្រទេសនេប៉ាល់ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ១២៣ ផ្លូវP១៨ ភូមិ៤ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] BIKRAM KUNWAR "រស់" ម្ដាយឈ្មោះ [redacted] DEVI KUNWAR "រស់" ប្រពន្ធឈ្មោះ [redacted] លីណា "រស់" ជានីតិជន ទោសពីមុន: គ្មាន។ (ក្រៅឃុំ)

-ជាប់ចោទពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] ថារិន ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១១៧EoE1 ផ្លូវP១៨ ភូមិ៤ សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-មេធាវី [redacted] និងមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ជនរងគ្រោះឈ្មោះ [redacted] ថារិន ភេទប្រុស អាយុ ៤៧ឆ្នាំ, ឈ្មោះ [redacted] វណ្ណធី ភេទប្រុស និងជនជាប់ចោទឈ្មោះ [redacted] KUNWAR ( [redacted] យុនវ៉ា) ភេទប្រុស អាយុ ២៧ឆ្នាំ បានចូលហ៊ុនគ្នារកស៊ីនាំចូលរថយន្ត និងគ្រឿងបន្លាស់មកពីសហរដ្ឋអាមេរិក ដើម្បីមកលក់បន្តនៅប្រទេសកម្ពុជា និងបើកយានដ្ឋាន RDR ដោយជនរងគ្រោះឈ្មោះ [redacted] វណ្ណធី ជាអ្នកទិញរថយន្តពីសហរដ្ឋអាមេរិក ដឹកជញ្ជូនមកប្រទេសកម្ពុជា រីឯជនរងគ្រោះឈ្មោះ [redacted] ថារិន ជាអ្នកចាត់ចែងដឹករថយន្តតាមកុងទីន័រពីខេត្តព្រះសីហនុមករាជធានីភ្នំពេញ ចំណែកជនជាប់ចោទឈ្មោះ [redacted] KUNWAR [redacted] យុនវ៉ា) ជាអ្នកថែទាំយានដ្ឋាន RDR និងគ្រប់គ្រងបញ្ជីចំណូលចំណាយក្នុងក្រុមហ៊ុន។

រហូតដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] KUNWAR ([redacted] ឃុនវ៉ា) បានដកប្រាក់ក្រុមហ៊ុនចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ទៅចាត់ចែងលើបំណុលរបស់ខ្លួន ដោយគ្មានការអនុញ្ញាតពីម្ចាស់ភាគហ៊ុនឡើយ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ថារិន។ (ឯកសារលេខ ១/២)

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ៥៦២៧ អ.យ.ង ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ (ឯកសារលេខ: ១០/២)

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១១៧៨ អ.យ.ង ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ (ឯកសារលេខ: ២៧/៥)

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១៦៣៨ "ង១" ដ.ង ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។ (ឯកសារលេខ: ២៨/២)

## នាពេលសវនាការ

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) នៅចំពោះមុខចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ខ្លួនបានដាក់ទុនរកស៊ីនាំរថយន្ត និងគ្រឿងបន្លាស់រថយន្តពីសហរដ្ឋអាមេរិកមកលក់នៅប្រទេសកម្ពុជា ដោយបានចូលហ៊ុនគ្នាចំនួន ០៣នាក់ ដោយឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណធី បានឱ្យខ្លួនដាក់ប្រាក់ចំនួន ៣២.០០០ (សាមសិបពីរពាន់) ដុល្លារអាមេរិក ជាគោលការណ៍របស់ពួកគាត់តាំងពីឆ្នាំ២០១៦ មកម្លេះ ប៉ុន្តែខ្លួនមានក្រុមហ៊ុនរបស់ខ្លួនស្រាប់ ទើបពួកគាត់សម្រេចយកក្រុមហ៊ុនរបស់ខ្លួននេះ ដាក់ឈ្មោះបើកការរកស៊ីលក់រថយន្តនេះតែម្តងដែលមានឈ្មោះ RDR ដោយឈ្មោះ [redacted] វណ្ណធី ជាអ្នកទិញឡានពីសហរដ្ឋអាមេរិក ដឹកជញ្ជូនមកប្រទេសកម្ពុជា, ឈ្មោះ [redacted] ថារិន មានតួនាទី Clear ពន្ធគយ និងដឹកឡានពីខេត្តព្រះសីហនុចូលមកភ្នំពេញ ចំណែកខ្លួនជាអ្នកមើលថែឃ្លាំងរថយន្ត, ឈរលក់ និងគ្រប់គ្រងបញ្ជីចំណូលចំណាយក្នុងក្រុមហ៊ុន។ នៅពាក់កណ្តាលឆ្នាំ២០១៨ ឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណធី បានឱ្យខ្លួនយកឈ្មោះ ក្រុមហ៊ុនទៅខ្ចីប្រាក់គេមកបង្កើនដើមទុន ដើម្បីឱ្យការដឹកជញ្ជូនក្នុងអាជីវកម្មមានភាពរហ័ស ចំណែកពួកគេក៏យកឈ្មោះក្រុមហ៊ុនទៅខ្ចីរកប្រាក់គេខាងក្រៅដែរ ពេលនោះខ្លួនបានប្រាប់ទៅពួកគាត់ថា ខ្លួនរកប្រាក់មិនបានទេ តែឈ្មោះ [redacted] ថារិន បានឱ្យខ្លួនយកប្លង់ផ្ទះរបស់ប្រពន្ធរបស់ខ្លួនទៅដាក់បញ្ចាំនៅធនាគារ ដើម្បីយកប្រាក់មកឱ្យក្រុមហ៊ុនសិន ដោយក្រុមហ៊ុនជាអ្នកទទួលខុសត្រូវបង់ការប្រាក់ឱ្យធនាគារ បន្ទាប់មកខ្លួនបានព្យាយាមនិយាយជាមួយប្រពន្ធ ទើបគាត់ព្រម លុះដល់ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៨ បានបញ្ចាំផ្ទះនៅធនាគារឯកទេស DGB បានប្រាក់ចំនួន ៥៩.០០០ (ហាសិបប្រាំបួនពាន់) ដុល្លារអាមេរិក ពេលនោះឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណធី បានប្រាប់ខ្លួនឱ្យផ្ញើប្រាក់ទាំងអស់ទៅអាមេរិកតាមរយៈការផ្ទេរទៅកាន់ធនាគារ ABA BANK លេខ ០០០ ៤២៦ ៥០១ មានឈ្មោះ [redacted] SAMNAGN ([redacted] សំណាង) រស់នៅខេត្តបាត់ដំបង ដែលគេមានភ្នាក់ងារដកប្រាក់នៅសហរដ្ឋអាមេរិក ហើយឈ្មោះ [redacted] វណ្ណធី ក៏បានឆ្លើយតបតាមសារ (What App Group) ថា គាត់បានទទួលរួចហើយ។ ក្រោយមកឈ្មោះ [redacted] ថារិន បានឈ្លោះជាមួយឈ្មោះ [redacted] វណ្ណធី ក្នុងក្រុមហ៊ុន ស្រាប់តែនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] ថារិន បានសម្រេចចិត្តបិទក្រុមហ៊ុន RDR Company តាមរយៈការផ្ញើសារចូលក្នុងគ្រុប What App ដោយមិនបានសួរនាំខ្លួនទេ ស្របពេលនោះខ្លួនបានស្នើសុំពួកគាត់កុំឱ្យបិទក្រុមហ៊ុន ដោះស្រាយបញ្ហាផ្ទាល់ខ្លួនសិនទៅ តែពួកគាត់មិនព្រម និងបានសម្រេចចិត្តដោយគ្មានការយល់ព្រមពីខ្លួនឡើយ។ ដំណឹងនេះបានដឹងដល់ប្រពន្ធខ្លួន ហើយគាត់បានទាមទារឱ្យក្រុមហ៊ុនយកប្រាក់ទៅរំលស់យកប្លង់ផ្ទះរបស់ខ្លួនវិញ ពេលនោះដោយមានការយល់ថា ក្រុមហ៊ុនលែងដំណើរការ ដោយសារឈ្មោះ [redacted] ថារិន ឈ្លោះគ្នាជាមួយឈ្មោះ [redacted] វណ្ណធី ហើយការប្រាក់ធនាគារត្រូវបង់ជាប្រចាំខែ បើរង់ចាំក្រុមហ៊ុននឹងខាតលើការបង់ការប្រាក់នេះទៀត ទើបនៅថ្ងៃទី២២ ខែមេសា

ឆ្នាំ២០១៩ ក្រុមហ៊ុនបានដកប្រាក់ទៅលោះយកប្លង់ផ្ទះខាងលើវិញ។ រហូតដល់ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] ថារិន បានឱ្យខ្លួនប្រគល់ឯកសារក្រុមហ៊ុនទាំងអស់ទៅឱ្យគាត់ ហើយខ្លួនក៏ប្រគល់របាយការណ៍ហិរញ្ញវត្ថុ ដែលខ្លួនបានកាន់ ចាប់ពីខែមករា ឆ្នាំ២០១៨ ដល់ខែឧសភា ឆ្នាំ២០១៩ ទៅឱ្យគាត់ និងស្នើសុំឱ្យគាត់ធ្វើវិសោធនកម្មលើចំណូលចំណាយក្រុមហ៊ុនទាំងមូលឱ្យមានសមតុល្យលើភាគហ៊ុនទាំងបី។ ដូច្នេះរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺឈ្មោះ [redacted] ថារិន ជាអ្នកគ្រប់គ្រងចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ តទៅ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ពួកខ្លួនទាំងបីនាក់ បានជួបគ្នាប្រជុំ ដើម្បីបិទក្រុមហ៊ុន ស្រាប់តែឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណនី បានស្នើសុំឱ្យខ្លួនចេញខាតចំនួន ២៦.៧៣៩,៣០ (ម្ភៃប្រាំមួយពាន់ប្រាំពីររយសាមសិបប្រាំបួន និងសាមសិបសេន) ដុល្លារអាមេរិក ដែលជាចំនួនខាតបង់តាំងពីពួកគាត់រកស៊ីពីរនាក់មកម្លេះ តែខ្លួនបដិសេធ ព្រោះពេលនោះខ្លួនមិនទាន់បានចូលហ៊ុនជាមួយពួកគាត់នោះទេ។ ខ្លួនចូលហ៊ុនជាមួយគាត់ចាប់ពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៩ រហូតដល់បិទក្រុមហ៊ុន គឺខាតសរុបចំនួន ២២.០៩៣,៥០ (ម្ភៃពីរពាន់កៅសិបបី និងហាសិបសេន) ដុល្លារអាមេរិក ចែកជាបីស្មើ ៧.៣៦៤,៥ (ប្រាំពីរពាន់បីរយហុកសិបបួន និងហាសិបសេន) ដុល្លារអាមេរិក តែប៉ុណ្ណោះ។ ចំពោះប្រាក់នេះ គឺខ្លួនឯកភាពប្រគល់ជូនពួកគាត់ តែពួកគេមិនព្រមយក ហើយបាននាំគ្នាចាកចេញពីក្រុមការងារអស់ (What App Group) ក្រោយមកស្រាប់តែឈ្មោះ [redacted] ថារិន ដាក់ពាក្យប្តឹងខ្លួនតែម្តង។ ឈ្មោះ [redacted] ថារិន បានប្តឹងខ្លួនថា បានដកប្រាក់ក្រុមហ៊ុន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ដោយមិនបានសុំការអនុញ្ញាត និងជូនដំណឹងជាមុន ចំពោះការប្តឹងចោទប្រកាន់នេះ គឺបំភ្លើសទាំងស្រុង ដោយហេតុថា ប្រាក់ខាងលើនេះ គឺក្រុមហ៊ុនបានដកសងទៅធនាគារវិញ ហើយខ្លួនបានប្រាប់ក្រុមការងារតាម What App Group រួចហើយ ម្យ៉ាងវិញទៀតការដកប្រាក់នេះតាំងពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ គឺក្រុមហ៊ុននៅដំណើរការធម្មតាមិនមានបញ្ហាទេ ហើយខ្លួនក៏នៅធ្វើការធម្មតា មិនបានរត់ទៅណាដូចការចោទប្រកាន់របស់ឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណនី ដោយពួកគេឱ្យខ្លួនចេញសងប្រាក់ដែលពួកគេខាតបង់ពីមុន តែខ្លួនបដិសេធ ទើបពួកគេប្តឹងខ្លួនតែម្តង។ ចំពោះប្រាក់ចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ខាងលើសុទ្ធតែជាប្រាក់ដែលប្រពន្ធខ្លួនបានដាក់បញ្ចាំប្លង់ផ្ទះ ចំណែកឈ្មោះ [redacted] ថារិន និងឈ្មោះ [redacted] វណ្ណនី មិនដែលបង្ហាញឯកសារដាក់ប្រាក់ចូលក្រុមហ៊ុនឱ្យខ្លួនបានឃើញម្តងណាឡើយ។

-ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះឈ្មោះ [redacted] ថារិន នៅចៅក្រមស៊ើបសួរថា ខ្លួន និងឈ្មោះ [redacted] វណ្ណនី បានរកស៊ីជាមួយគ្នាក្នុងនាមបងប្អូន ដើម្បីនាំរថយន្ត និងគ្រឿងបន្លាស់រថយន្តមកពីសហរដ្ឋអាមេរិក ដើម្បីលក់នៅកម្ពុជា។ ការរកស៊ីរបស់ពួកខ្លួន គឺជាលក្ខណៈគ្រួសារ ហើយមានការចំណេញ ឬខាតជារឿងធម្មតា។ ក្នុងអំឡុងពេលនោះ ខ្លួនបានជួលទីតាំង និងធ្វើការចំណាយអស់ដើមទុនមួយចំនួនធំ។ ក្រោយមកខ្លួនបានស្គាល់ឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) ជនជាតិនេប៉ាល់ ដោយគាត់មករស់នៅជិតផ្ទះរបស់ខ្លួន ហើយខ្លួនបានជួយគាត់លើការងារមួយចំនួន ហើយគាត់ និងប្រពន្ធឈ្មោះ ហួច លីណា បានរាប់អានគ្រួសារខ្លួនដូចពូ មីង និងក្មួយ។ ក្រោយមកឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) និងភរិយាបានបង្ហាញបំណងរកស៊ីជាមួយខ្លួនក្នុងការងារនាំឡាន និងគ្រឿងបន្លាស់នេះរួមជាមួយពួកខ្លួន។ ទោះបីពួកខ្លួនបានបង្ហាញពីស្ថានភាពនៃការរកស៊ីរបស់ខ្លួនថា មិនបានចំណេញ ក៏ឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) និងភរិយានៅតែទទូចចង់រកស៊ីជាប្រចាំ ហើយបានបង្ហាញថា ការតាំងចិត្តថា គាត់នឹងប្រឹងប្រែង និងគ្រប់គ្រងដើម្បីឱ្យចំណេញ។ ចុងក្រោយពួកខ្លួនបានឱ្យឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) ចូលរួម។ មុននឹងចូលរួមឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) បានឱ្យខ្លួនធ្វើរបាយការណ៍ដើមទុន និងបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ នៃការរកស៊ីនេះ ដោយពួកខ្លួនបានបង្ហាញយ៉ាងច្បាស់ថា ខ្លួនមិនទាន់ចំណេញទេ និងខាតបង់។ ឈ្មោះ [redacted] KUNWAR ([redacted] យុនវ៉ា) បានបង្ហាញឆន្ទៈយ៉ាងមុតមាំ ដោយពិភាក្សាជាមួយលោកស្រី ហួច លីណា ជាច្រើនលើកច្រើនសាររួចមកថា លោកនឹងចូលរួម ហើយលោកថែមទាំងបានបញ្ជាក់ថា លោកមិនមានរបរអ្វីទេ លោកនឹងធ្វើឱ្យការរកស៊ីនេះចំណេញនាពេលខាងមុខ

ដោយលោកនឹងជួយគ្រប់គ្រងផ្ទាល់។ លោកក៏បានដាក់ទុនជាបីដំណាក់កាល ក្រោយមកដំណើរការរកស៊ីរបស់ពួកខ្លួន ក្នុងនាមជាយានដ្ឋាន R&D មិនបានប្រសើរសោះ តែងតែជួបបញ្ហាហិរញ្ញវត្ថុញឹកញាប់ ហើយភាគីទាំងបីនាក់បានឯកភាពគ្នាខ្ចីលុយគេ តាមលទ្ធភាពរៀងៗខ្លួន ដើម្បីដាក់ចូលរកស៊ីក្នុងក្រុមហ៊ុន។ ពួកខ្លួនតែងតែខ្ចីលោក CASEY BARNETT, ឯកឧត្តម [redacted] ស៊ីផុល, លោកស្រី [redacted] ធីតា និងលោកម្នាក់ទៀតមិនចាំឈ្មោះ ដែលមានផ្ទះនៅផ្សារបែកក្អម ហើយលោក [redacted] វណ្ណធី ខ្ចីពីធនាគារ Canadia នៅកំពង់ចាម និងឈ្មោះ [redacted] KUNWAR ([redacted] ឃុនវ៉ា) ខ្ចីពីធនាគារឯកទេស។ ក្រោយមកនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) ក្នុងនាមជាអ្នកគ្រប់គ្រងគណនេយ្យ និងហិរញ្ញវត្ថុបានលួចដកប្រាក់របស់ក្រុមហ៊ុនចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក យកសងបំណុលដែលខ្លួនបានរ៉ាប់រងខ្ចីពីធនាគារ DGB ដោយមិនបានជូនដំណឹង ឬ សុំការអនុញ្ញាតជាមុនពីខ្លួន និងឈ្មោះ [redacted] វណ្ណធី ដែលជាម្ចាស់ភាគហ៊ុនឡើយ។ ម្យ៉ាងទៀតចាប់តាំងពីពេលនោះមកឈ្មោះ AMRIT KUNWAR (អមរិត ឃុនវ៉ា) បានចាកចេញពីការគ្រប់គ្រងក្រុមហ៊ុនតាមការទទួលខុសត្រូវទាំងស្រុងតែម្តង ហើយការព្យាយាមគេចវេះមិនបំពេញកាតព្វកិច្ចពាក់ព័ន្ធនានាទាំងអស់។

-ក្រឡាបញ្ជីអានពាក្យសុំដកពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ថារិន។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការរួចមក តំណាងអយ្យការយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] KUNWAR (អមរិត ឃុនវ៉ា) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ពីបទ *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ប្រាកដមែន។ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដុកនៅដដែល និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-សហមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានប្រហាក់ប្រហែលគ្នាថា ក្រោយពីបានស្តាប់ការសាកសួរដេញដោលនាពេលសវនាការរួចមក យល់ឃើញថា តាមភស្តុតាង និងអង្គហេតុ កូនក្តីខ្លួនឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) ដែលមានតួនាទីជាអ្នកទទួលបន្ទុកគ្រប់គ្រងឃ្លាំង និងគណនីហិរញ្ញវត្ថុក្រុមហ៊ុន និងជាអ្នកទទួលបន្ទុកទូទាត់បំណុលរៀងរាល់ខែ ដោយមានការទទួលស្គាល់ពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថារិន។ ហើយកូនក្តីខ្លួនតែងតែរ៉ាប់រងបង់រៀងរាល់ដល់ពេលកំណត់ ក្នុងនាមជាអ្នកកាន់គណនី និងហិរញ្ញវត្ថុ។ ដូច្នេះកូនក្តីខ្លួនឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) ធ្វើការក្នុងនាមក្រុមហ៊ុនបានដកប្រាក់សងបំណុលធនាគារ ដែលក្រុមហ៊ុនបានជំពាក់ធនាគារនោះ ពុំមែនជាបទល្មើសដែលត្រូវចោទប្រកាន់ទេ។ ផ្អែកតាមបញ្ញត្តិមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានចែងថា "ប្រសិនបើតុលាការយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសទេ ឬ ក៏ជនជាប់ចោទគ្មានកំហុសទេ ជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ" ហេតុដូច្នេះ ស្នើសុំតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានចម្លើយជនរងគ្រោះ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យលើឯកសារ និងភស្តុតាងនានា។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១/.ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ, ជនរងគ្រោះ និងពិនិត្យភស្តុតាងឃើញថា កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] KUNWAR (អមរិត ឃុនវ៉ា) ពិតជាបានយកប្រាក់ក្រុមហ៊ុនចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ទៅចាត់ចែងលើបំណុលដែលជាបញ្ហាផ្ទាល់ខ្លួន ដោយមិនមានការអនុញ្ញាតពីម្ចាស់ភាគហ៊ុន ដែលជាជនរងគ្រោះឡើយ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] KUNWAR (អមរិត ឃុនវ៉ា) បានធ្វើឱ្យខូចសណ្តាប់ធ្នាប់ និងរបៀបរៀបរយសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អ្នកដទៃ គប្បីតុលាការសម្រេចដាក់ទោសជននេះតាមច្បាប់។

២/.នៅក្នុងរឿងនេះជនរងគ្រោះឈ្មោះ [redacted] ថារិន បានដកពាក្យបណ្តឹងឈប់ប្តឹងទាមទារសំណងការខូចខាត និងជម្ងឺចិត្តទៀតហើយ នោះគប្បីតុលាការមិនពិចារណាលើសំណងរដ្ឋប្បវេណី។

៣/.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការស្នើសុំតម្កល់បទចោទប្រកាន់ទុកជាបានការទាំងមូល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់នោះមានលក្ខណៈសមហេតុផលហើយ គប្បីតុលាការពិនិត្យសម្រេចតាមច្បាប់។

៤/.សហមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំតុលាការសម្រេចឱ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទប្រកាន់ នោះគប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

៥/.មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិនេប៉ាល់ ពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

១/.ផ្តន្ទាទោសឈ្មោះ [redacted] KUNWAR [redacted] ឃុនវ៉ា) ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិនេប៉ាល់ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ តែទោសនេះព្យួរធម្មតា ពីបទ: **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៧ មាត្រា ១០៧ មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២/.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងកំបាំងមុខជនជាប់ចោទ សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២

| | |
|---|---|
| បានឃើញ | |
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner